00249815

C26/5/2

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| **ឈ្មោះសំណុំរឿង:** | **ខៀវ សំផន** |
| **ដាក់តម្កល់ជូន:** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទដាក់ឯកសារ:** | ថ្ងៃទី៤ ធ្នូ ២០០៨ |
| **ភាគីអ្នកតម្កល់:** | ក្រុមការពារក្តី |
| **ភាសា:** | ភាសាដើមជាភាសាបារាំង (បកប្រែក្រៅផ្លូវការជាភាសាខ្មែរ) |
| **ប្រភេទឯកសារ:** | **សាធារណៈ** |

ឯកសារដែលបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / DEC / 2008
ម៉ោង (Time/Heure): 08:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

## សំណើដាយថាហេតុ និងបន្ទាន់បំផុតដើម្បីស្នើសុំអោយមានការដោះលែងឲ្យមានសេរីភាព

---

<u>**បញ្ជូនដោយ:**</u>

**មេធាវីរបស់លោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGÈS

<u>**ជំនួយការ:**</u>

អ្នកស្រី សេង សុជាតា

កញ្ញា Charlotte MOREAU

<u>**បញ្ជូនទៅ:**</u>

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K. K. Ratanak

00249816



C261512

# គោរពជូនអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

1. ដោយអនុលោមតាមមាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សហមេធាវីការពារក្តីសូមដាក់សំណើនេះជាបន្ទាន់បំផុត។ សំណើនេះត្រូវបានដាក់ជាបន្ទាន់បំផុតនិងជាយថាហេតុ និងក្នុងក្របខ័ណ្ឌនៃសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នដែលបានដាក់ ដោយក្រុមការពារក្តីកាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ។

## II. បទបញ្ញត្តិគតិយុត្តិសមស្រប

### ក) សិទ្ធិដែលចែងដោយរដ្ឋធម្មនុញ្ញត្រូវបានបំពាន

- "បុគ្គលគ្រប់រូបមានសិទ្ធិ (...)មានសិទ្ធិមានសេរីភាព(...)"[1] និង"ការចោទប្រកាន់ ការចាប់ខ្លួន (...) ការឃុំខ្លួន នឹងអាចធ្វើទៅបានលុះណាតែសមស្របតាមបញ្ញត្តិច្បាប់។" [2]
- "ករណីមានមន្ទិលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។[3]"

### ខ) នីត្យានុកូលភាពនៃនីតិវិធីបានចោទជាបញ្ហា

- មាត្រា ២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "ក្នុងករណីមានការឃុំខ្លួនបណ្តោះអាសន្ន សាលដីកាត្រូវធ្វើឡើង ក្នុងអំឡុងរយៈពេល១៥ថ្ងៃគិតចាប់ពីពេលដែលក្រឡាបញ្ជីរបស់សភាស៊ើបសួរទទួលបានសំណុំរឿង។ ផុតកំណត់រយៈពេលនេះ ជនត្រូវចោទត្រូវបានដោះលែងអោយមានសេរីភាព លើកលែងតែករណីមានការបង្គាប់អោយមានការផ្ទៀងផ្ទាត់ ឬករណីដែលសាលដីកាមិនអាចប្រកាសបានក្នុងពេលកំណត់ដោយសារ តែកាលៈទេសៈដែលមិនអាចព្យៀងទុកជាមុន ឬមិនអាចជំនះបាន"

---

[1] មាត្រា៣២ នៃរដ្ឋធម្មនុញ្ញ

[2] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ

[3] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ

- យោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(PIDCP) ដែលជាសន្ធិសញ្ញាដែលអនុវត្តដោយផ្ទាល់ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) មាត្រា៩(៤) ចែងថា "ជនណាក៏ដោយដែលត្រូវបានដកហូតសេរីភាពដោយសារការចាប់ខ្លួន ឬឃុំខ្លួន មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីអោយតុលាការសម្រេចដោយមិនបង្អង់អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ដោះលែងអោយនៅក្រៅឃុំ បើសិនជាការឃុំខ្លួននោះមិនស្របច្បាប់។"[4]

## គ) អំណាចចាំបាច់ក្នុងការធ្វើអន្តរាគមន៍

### អំណាចផ្ទាល់របស់ប្រធានអង្គបុរេជំនុំជម្រះ

2. ដោយអនុលោមតាមមាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា "ប្រធានសភាស៊ើបសួរ (...) ផ្ទៀងផ្ទាត់មើលជាអាទិ៍លក្ខខណ្ឌនៃការអនុវត្តបទបញ្ញត្តិទាក់ទិននឹង ការឃុំខ្លួនបណ្តោះអាសន្ន និង ដីកាតុលាការផ្សេងៗ (...) គាត់រាំប់រងកុំឲ្យនីតិវិធីទាំងឡាយ មានការយឺតយ៉ាវមិនសមហេតុផល"។

### សមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងការដោះស្រាយបណ្តឹងឧទ្ធរណ៍

3. យោងតាមមាត្រា១០៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា "អំណាចតុលាការ គឺជាអំណាចឯករាជ្យមួយ។ អំណាចតុលាការគឺដើម្បីធានានូវអនាគតិ និងការពារសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ (...)។ អំណាចនេះត្រូវបានផ្តល់អោយដល់តុលាការកំពូល និងដល់យុត្តាធិការគ្រប់ប្រភេទ និងគ្រប់លំដាប់ថ្នាក់"។ ដោយស្របតាមមាត្រា១១០នៃរដ្ឋធម្មនុញ្ញ "ចៅក្រមត្រូវតែអនុវត្តភារកិច្ចរបស់ខ្លួនដោយគោរពតាមច្បាប់យ៉ាងម៉ត់ចត់ និងតាមសតិស្មារតីនិងសម្បជញ្ញៈ។

4. យោងតាមមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា "រាល់ពេលដែលសភាស៊ើបអង្កេតទទួលពាក្យបណ្តឹង សភាស៊ើបអង្កេតពិនិត្យលើនិយ័តកម្មរបស់នីតិវិធី និងធានា នូវ

[4] បទបញ្ញត្តិនេះមានចែងផងដែរនៅក្នុងមាត្រា ៥(៤) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ដែលពិតមែនតែមិនអាចអនុវត្តបានដោយផ្ទាល់ ក៏អាចប្រើជាការបានដើម្បីតម្រង់ផ្លូវក្នុងការសម្រេចសេចក្តីនេះ ៖ "បុគ្គលគ្រប់រូប ដែលត្រូវបានដកហូតសេរីភាព (...) មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីដើម្បីអោយតុលាការសម្រេចក្នុង រយៈពេលឆាប់រហ័ស អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ដោះលែងអោយនៅក្រៅឃុំ បើសិនជាការឃុំខ្លួននោះមិនស្របច្បាប់"

ការប្រព្រឹត្តទៅបានល្អនៃនីតិវិធី។ សភាស៊ើបអង្កេតអាចសម្រេចដោយបញ្ញាតិទុកជាមោឃៈនូវនីតិវិធីទាំងស្រុងឬតែមួយផ្នែក បើសិនជាសភាស៊ើបអង្កេតកត់សម្គាល់ឃើញមានមូលហេតុនៃមោឃភាព។

5. នៅក្នុងច្បាប់អន្តរជាតិ និងតាមយុត្តិសាស្ត្រ គេចាត់ទុកផងដែរថាតុលាការមួយត្រូវបានចាត់ទុកថាមានអំណាចធ្វើការកត់ត្រាជាលក្ខណៈផ្លូវការ ដែលចាំបាច់ដល់ការអនុវត្តសមត្ថកិច្ចចំបងរបស់ខ្លួន"[5] ទោះបីជាអំណាចនេះត្រូវបានចែងឬមិនបានចែងដោយច្បាប់ក្តី អោយតែវាចាំបាច់សំរាប់ធានាអោយមានយុត្តិធម៌ប្រកបដោយសមធម៌។[6]

## III. មូលហេតុសំអាងនៃពាក្យបណ្តឹង

6. ក្រុមការពារក្តីចាត់ទុកថា លោក ខៀវ សំផន បច្ចុប្បន្នកំពុងស្ថិតក្នុងការឃុំខ្លួនដោយបំពាន ដោយសម្អាងលើឯកសារដែលគ្មានតម្លៃ និងក្នុងក្របខណ្ឌនៃនីតិវិធីដែលមានភាពយឺតយ៉ាវ។ ការរំលោភបំពានទាំងនេះ ត្រូវបានលើកឡើងក្នុងសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន[7]។ អង្គបុរេជំនុំជម្រះបានទទួលពាក្យបណ្តឹងពីអនីយ័តកម្មទាំងនេះ ហើយអង្គបុរេជំនុំជម្រះត្រូវតែសម្រេចលើមូលភាពក្នុងពេលបន្តិចទៀតនេះ។ សំណើនេះត្រូវបានធ្វើឡើងនៅក្នុងក្របខណ្ឌនេះ និងជាយថាហេតុ។

7. ដោយផ្អែកទៅលើអំណាចផ្ទាល់ខ្លួនដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អោយ ប្រធានអង្គបុរេជំនុំជម្រះត្រូវតែ"ផ្ទៀងផ្ទាត់មើល ជាអាទិ៍លក្ខខណ្ឌនៃការអនុវត្តបទបញ្ញត្តិទាក់ទិននឹងការឃុំខ្លួនបណ្តោះអាសន្ន និងដីកាតុលាការផ្សេងៗ (...) គាត់រ៉ាប់រងកុំឲ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវមិនសមហេតុផល"។

8. ក្រុមការពារក្តីបានលើកឡើងថា តាមអត្ថន័យ ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការមួយដែល "ដាក់ទោស ដោយផ្តល់ការលំបាកជាក់លាក់ ការឈឺចាប់ពិតប្រាកដដល់ជនម្នាក់ដែលមិនត្រូវបាន

---

[5] វដ្តអាជ្ញា C.Tihomir Blaskic, IT-95-14-AR108bis សាលដីកាទាក់ទិនទៅនឹងសំណើរបស់សាធារណៈរដ្ឋ ក្រូអាស៊ី ដើម្បីស្នើសុំអោយពិនិត្យលើសេចក្តីសម្រេចចេញថ្ងៃទី ១៨ កក្កដា ១៩៩៧ ដោយអង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី២៩ តុលា១៩៩៧ កថាខណ្ឌទី៣៣

[6] អត្ថបទដដែល កថាខណ្ឌទី២៥

[7] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី៤ ធ្នូ ២០០៨

សន្និដ្ឋថាមានទោស ហើយផ្ទុយទៅវិញអាចជាជនស្លូតត្រង់ម្នាក់ ហើយដែលវាយប្រហារ ទៅលើកិត្តិនាម លើមធ្យោបាយក្នុងការរស់នៅរបស់ជននេះ និងលើបុគ្គលផ្ទាល់តែម្តង"។[8]

9. ក្នុងរឿងនេះ លោកខៀវ សំផន ទទួលរងការរំលោភបំពានលើសិទ្ធិរបស់គាត់ ដោយផ្ទុយនឹងច្បាប់ច្បាស់ណាស់ ជាពិសេសសិទ្ធិរបស់គាត់ក្នុងការការពារខ្លួន និងសិទ្ធិទទួលបានការកាត់ក្តីក្នុងរយៈពេលមួយសមស្រប ដែលត្រូវធ្វើឡើងតាំងពីច្រើនខែមកហើយ។ ក្នុងក្របខណ្ឌបណ្តឹងឧទ្ធរណ៍លើការបកប្រែ អង្គបុរេជំនុំជម្រះត្រូវតែសម្រេចសេចក្តីក្នុងពេលដ៏ខ្លីខាងមុខនេះ លើការបកស្រាយលើនីត្យានុកូលភាពរបស់នីតិវិធីទាំងមូល និងអាចសម្រេចពីមោឃភាពនៃការការចោទប្រកាន់ និងពីលក្ខណៈបំពាននៃការឃុំខ្លួន។ ផ្ទុយមកវិញ និងពីរលើកមកហើយ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ពីភាពស្របច្បាប់នៃការឃុំខ្លួន និងដោយដោយគ្មានសំអាងហេតុត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេតទទួលបន្ទុកបានត្រឹមតែស៊ើបអង្កេតពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មប៉ុណ្ណោះ។

10. ក្រុមការពារក្តីយល់ឃើញថា ស្ថានភាពនេះគឺមានលក្ខណៈបន្ទាន់ខ្លាំងណាស់ ហើយស្ថានភាពនេះបានត្រឹមតែអូសបន្លាយរយៈពេលវែងជ្រុល។ ដូច្នេះដើម្បីការពារសិទ្ធិរបស់ជនត្រូវចោទ វាជាការចាំបាច់ណាស់ ក្នុងការដាក់ពាក្យបណ្តឹងមួយដែលមានលក្ខណៈបន្ទាន់ និងពិសេសដោយឡែកមួយ ។ ក្រុមការពារក្តីស្នើសុំអោយប្រធានអង្គបុរេជំនុំជម្រះ ដែលតំណាងអោយអំណាចតុលាការ និងដោយយោងលើអំណាចផ្ទាល់ខ្លួនដែលគាត់មាននៅក្នុងអង្គបុរេជំនុំជម្រះ ចេញវិធានការណ៍ តែមួយគត់ដែលដាក់អោយគោរព និងបង្គាប់ជាបន្ទាន់អោយដោះលែងលោក ខៀវ សំផន អោយមានសេរីភាពបណ្តោះអាសន្ន។

11. ដូច្នេះ សហមេធាវីការពារក្តីសូមឲ្យលោកប្រធានអង្គបុរេជំនុំជម្រះ ដែលជាអ្នកតំណាងនៃអំណាចតុលាការ និងយោងតាមអំណាចផ្ទាល់ខ្លួនដែលមានក្នុងអង្គបុរេជំនុំជម្រះ មេត្តាចាត់វិធានការណ៍តែមួយគត់ដែលបានដាក់កំហិត ព្រមទាំងបង្គាប់ឲ្យមានការដោះលែងលោក ខៀវ សំផន ជាបណ្តោះអាសន្ន ជាបន្ទាន់។

[8] Faustin Hélie : តុលាការស៊ើបអង្កេតឧក្រិដ្ឋកម្ម ១៨៤៦ IV លេខ១៩៤៨

## IV. សំណើ

12. បានឃើញសារណាឧទ្ធរណ៍ដែលបានដាក់ដោយក្រុមការពារក្តី ថ្ងៃទី២២កក្កដា ២៧វិច្ឆិកា និង ៥ធ្នូ ២០០៨

13. យល់ឃើញថា **ភាពបន្ទាន់** និង **ការរំលោភបំពាន** ដែលផ្ទុយនឹងច្បាប់ជាក់ស្តែងលើសិទ្ធិរបស់ក្រុមការពារក្តី សហមេធាវីការពារក្តីសំណូមពរដោយទទូចអោយប្រធានអង្គបុរេ ជំនុំជម្រះ ក្នុងកិច្ចរក្សានិងការពារ បង្គាប់អោយដោះលែងលោក ខៀវ សំផន អោយមានសេរីភាព បណ្តោះអាសន្ន ក្រោមលក្ខខណ្ឌដែលគាត់យល់ឃើញថាសមស្រប រង់ចាំដល់ពេលមានសេចក្តីសម្រេចលើមូលភាពនៃបណ្តឹងឧទ្ធរណ៍។

មេធាវី ស សូវាន

មេធាវី Jacques VERGES